ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

===

**សាលាដំបូង ខេត្តស្វាយរៀង**

សំណុំរឿងរដ្ឋប្បវេណីលេខ:១៥៣

ចុះថ្ងៃទី១៣ខែតុលាឆ្នាំ២០២១

សាលក្រមរដ្ឋប្បវេណីលេខ:១១៥(ខ)

ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូង ខេត្តស្វាយរៀង

-បានបញ្ចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ខែកញ្ញាឆ្នាំ២០២២

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម ថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានសមាសភាពចូលរួមដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តស្វាយរៀង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តស្វាយរៀង

**ដើម្បី:** ធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ:១៥៣ចុះថ្ងៃទី១៣ខែតុលា ឆ្នាំ២០២១ ។

រវាងដើមចោទឈ្មោះ [redacted] សាធាន ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានទីលំនៅបច្ចុប្បន្ន[redacted],ឪពុកឈ្មោះ [redacted] សម្បត្តិ (រ) ម្តាយឈ្មោះ [redacted] សារៀន (រ) ប្រពន្ធឈ្មោះ [redacted] សិន មានកូន០២នាក់ ។មេធាវីតំណាងដោយអាណត្តិគ្មាន ។

និងចុងចម្លើយឈ្មោះ [redacted] HUO ភេទប្រុស ជនជាតិចិន មុខរបរនាយកគ្រប់គ្រងក្រុម [redacted] មានទីតាំងផ្លូវជាតិលេខ[redacted] ។ មេធាវីតំណាងដោយអាណត្តិ [redacted] ។

### អង្គហេតុនិងចំណុចវិវាទ

ក.ការទាមទាររបស់ដើមចោទ:

-ប្តឹងសុំឲ្យចុងចម្លើយឈ្មោះ [redacted] HUO ភេទប្រុស ជនជាតិចិន ជានាយកគ្រប់គ្រងក្រុមហ៊ុន[redacted] ដើម្បីទាមទារប្រាក់ឈ្នួលរហូតដល់ចប់កិច្ចសន្យាការងារ ប្រាក់ខែចុងក្រោយ ទូទាត់ប្រាក់ចំណាចអតីតភាពការងារ ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ និងសោហ៊ុយជម្ងឺចិត្តដូចមានចែងក្នុងច្បាប់ស្តីពីការងារ ។

### អង្គហេតុជាមូលហេតុ

កាលពីថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០១២ ខ្លួនបានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន[redacted]មានតួនាទីជាកម្មករចាំឃ្លាំង នៅពេលបម្រើការងារខាងក្រុមហ៊ុនបានចោទប្រកាន់មកលើរូបខ្លួន ថា ខ្ជិល ម៉ោងការងារលេងទូរស័ព្ទ បានហៅខ្លួនទៅធ្វើកិច្ចសន្យាចំនួន២ដង ។លុះនៅថ្ងៃទី២០ខែសីហាឆ្នាំ២០២១ នេះស្រាប់តែក្រុម

ហ៊ុនបានបញ្ឈប់ខ្លួនពីការងារ បានចោទប្រកាន់មកលើរូបខ្លួន ថា ខ្ជិល មើលការងារលេងទូរស័ព្ទ អង្គុយលើ ទំនិញ ទាំងដែលខ្លួនមិនបានធ្វើ ដោយពុំមានជូនដំណឹងខ្លួនជាមុន ដោយមិនបានទូទាត់ប្រាក់ឈ្នួលរហូតដល់ចប់ កិច្ចសន្យាការងារ ប្រាក់ខែចុងក្រោយ ទូទាត់ប្រាក់បំណាច់អតីតភាពការងារ ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែល នៅសល់ និងសោហ៊ុយជម្ងឺចិត្ត ដូចមានក្នុងច្បាប់ស្តីពីការងារ ។

ខ. ការអះអាងរបស់គូភាគី

១.ការអះអាងរបស់ភាគីដើមចោទ:

-ដើមចោទឈ្មោះ [redacted] សាបាន បានធ្វើសេចក្តីថ្លែងការណ៍ថា មកទល់និងពេលនេះខ្លួននៅតែប្តឹងពី ក្រុមហ៊ុន [redacted] ទាមទារប្រាក់ចំនួន៥ចំណុច គឺ ប្រាក់ជូនដំណឹង ប្រាក់ខែចុងក្រោយ ប្រាក់បំណាច់អតីតភាពការងារ ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ និងសោហ៊ុយខាងបង់ពេលវេលា និងជម្ងឺចិត្ត សរុបទាំងអស់ចំនួន ៦០០០ ដុល្លារអាមេរិក ដោយសំអាងហេតុថា ក្រុមហ៊ុនបានបញ្ឈប់ខ្លួនដោយគ្មានមូលហេតុ ពុំបានជូនដំណឹងខ្លួនជាមុន មិនបើកប្រាក់អត្ថប្រយោជន៍ចំនួន៥ ចំណុចខាងលើនិងប្រាក់ខាតបង់ពេលវេលា និងជម្ងឺចិត្ត មកឱ្យខ្លួន តាមច្បាប់ស្តីពីការងារនោះឡើយ ។

២.ការអះអាងរបស់ចុងចម្លើយ

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទាររបស់ដើមចោទគឺជាការទាមទារមិនត្រឹមត្រូវ ពីព្រោះថា ដើមចោទជាបុគ្គលិកដែលមានកំហុសច្រើនលើកច្រើនសារ ទោះបីជាក្រុមហ៊ុនបានណែនាំគាត់ជាច្រើនលើកច្រើនសារ ក៏គាត់មិនធ្វើការកែប្រែកំហុសនោះទេ ការប្រព្រឹត្តកំហុសដដែលៗរបស់គាត់នេះ ធ្វើឱ្យក្រុមហ៊ុនធ្វើការព្រមានចំនួន៤ដង ការប្រព្រឹត្តកំហុសរបស់ដើមចោទនេះ ដើមចោទក៏បានទទួលស្គាល់ផងដែរ ខាងក្រុមហ៊ុនមានលិខិតស្នាម និងសាក្សី បង្ហាញជូនតុលាការ ឱ្យជឿថាឈ្មោះ [redacted] សាបាន បានប្រព្រឹត្តកំហុស សមស្របនិងគោលការផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងការអនុវត្តន៍គោលការបណ្តេញចេញ ហើយប្រាក់បំណាច់ដែលឈ្មោះ [redacted] សាបាន ទទួលបានគឺប្រាក់ខែចុងក្រោយស្មើនឹង១១៨.៧៧ ដុល្លារ ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ចំនួន១៧ថ្ងៃ ស្មើនឹង១៤៧.៧ដុល្លារ,ប្រាក់ទ្រទ្រង់សុខភាពចំនួន៥ដុល្លារ,ប្រាក់រង្វាន់បំណាច់ឆ្នាំ១០ដុល្លារ,ប្រាក់ឧបត្ថម្ភអាហារ ៨ដុល្លារ និងប្រាក់ឧបត្ថម្ភធ្វើដំណើរចំនួន១៦ថ្ងៃស្មើនិង១៣ដុល្លារ រីឯប្រាក់ផ្សេងពីនេះ ដើមចោទមិនត្រូវទទួលបានទេ ពីព្រោះដើមចោទមានកំហុស ក្រុមហ៊ុនព្រមានចំនួន៤ដងហើយ ដូច្នេះក្រុមហ៊ុនមិនចាំបាច់ជូនដំណឹងដល់ដើមចោទទៀតទេ ។

-ដើមចោទឈ្មោះ [redacted] សាបាន បានធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនមិនអាចទទួលយកប្រាក់ដែលក្រុមហ៊ុនប្រគល់ឱ្យខ្លួនចំនួន២ចំណុចនេះបានទេ គឺខ្លួនទាមទារចំនួន៥ចំណុចដដែល ។

គ.ភស្តុតាងរបស់គូភាគី

១.ភស្តុតាងរបស់ភាគីដើមចោទមាន:

ក.ភស្តុតាងជាឯកសារ

-ពាក្យបណ្តឹងចុះថ្ងៃទី០២ខែកញ្ញាឆ្នាំ២០២១ ចំនួន២ច្បាប់ ។

-កំណត់ហេតុស្តីពីការសាកសួរព័ត៌មានចុះថ្ងៃទី០៣ខែកញ្ញាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

-កំណត់ហេតុនៃការផ្សះផ្សាវិវាទបុគ្គល ចុះថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

២.ភស្តុតាងរបស់ចុងចម្លើយ

ខ.ភស្តុតាងជាឯកសារ

-កិច្ចសន្យាសាកល្បងការងាររយៈពេលកំណត់៣ខែ ចំនួន១ច្បាប់។

-កិច្ចសន្យាការងារមានរយៈពេលកំណត់(ចំពោះកម្មករពេញសិទ្ធិ)ចំនួន២ច្បាប់ ។



Scanned with CamScanner

-កំណត់នៃការព្រមានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៤ខែមករាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

-កំណត់នៃការព្រមានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

-កំណត់នៃការព្រមានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ២០២១ ចំនួន១ច្បាប់ ។

-កំណត់នៃការព្រមានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២០ខែសីហាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

-លិខិតបញ្ឈប់ពីការងារ ចុះថ្ងៃទី២០ខែសីហាឆ្នាំ២០២១ ចំនួន១ច្បាប់ ។

៣. ចំណុចវិវាទ: ដើមចោទប្តឹងទាមទារប្រាក់អត្ថប្រយោជន៍ចំនួន៥ចំណុច តែភាគីចុងចម្លើយយល់ព្រមប្រគល់ឱ្យតែ២ចំណុចគឺ ប្រាក់ខែចុងក្រោយ ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ។

## សំអាងហេតុ

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគីក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិនិត្យលើភស្តុតាងនានាឃើញថា:

-ដើមចោទឈ្មោះ [redacted] សាបាន ពិតជាបានចូលបម្រើការងារជាបុគ្គលិកក្រុមហ៊ុន [redacted] កាលពីថ្ងៃទី១០ខែមេសាឆ្នាំ២០១២ រហូតដល់ថ្ងៃទី២០ខែសីហាឆ្នាំ២០២១ ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ ។

-យោងតាមកំណត់នៃការព្រមានជាលាយលក្ខណ៍អក្សរចុះថ្ងៃទី១៤ខែមករាឆ្នាំ២០២១ , ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០២១ ,ចុះថ្ងៃទី១៣ខែកុម្ភៈឆ្នាំ២០២១ និងចុះថ្ងៃទី២០ខែសីហាឆ្នាំ២០២១ ហើយដើមចោទ បានផ្តិតមេដៃទទួលស្គាល់ដែរ ។

- ដើមចោទប្តឹងសុំឱ្យចុងចម្លើយ(ក្រុមហ៊ុន[redacted] ផ្តល់ប្រាក់ឈ្នួលរហូតដល់ថ្ងៃបញ្ចប់កិច្ចសន្យាការងារ ប្រាក់ខែចុងក្រោយ ប្រាក់បំណាច់អតីតភាពការងារ ប្រាក់ឈប់សម្រាប្រចាំឆ្នាំដែលនៅសល់ និងប្រាក់ជម្ងឺចិត្តសរុបចំនួន ៦០០០ (ប្រាំមួយពាន់)ដុល្លារ ។

-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានលើកឡើងថា ដើមចោទមានកំហុសក្នុងពេលបំពេញការងារ ខ្ជិល លេងទូរស័ព្ទ អង្គុយលើអីវ៉ាន់ ក្រុមហ៊ុនបានធ្វើលិខិតព្រមានជាលាយលក្ខណ៍អង្សរចំនួន៤ដងមុននិងបញ្ឈប់ការងារ(មាត្រា២៧និងមាត្រា៨២នៃច្បាប់ស្តីពីការងារ ) ។

- ដើមចោទទាមទារប្រាក់អត្ថប្រយោជន៍ចំនួន៥ចំណុចនោះ ក្រុមហ៊ុនមិនអាចប្រគល់ឱ្យបានទាំង៥ចំណុចនោះទេ គឺក្រុមហ៊ុនប្រគល់ជូនបានតែចំនួន២ចំណុចគឺ ប្រាក់ខែចុងក្រោយស្មើនឹង១១៨.៧៧ ដុល្លារ ប្រាក់ឈប់សម្រាកប្រចាំ ឆ្នាំដែលនៅសល់ចំនួន១៧ថ្ងៃស្មើនឹង១៤៧.៧ដុល្លារ ,ប្រាក់អត្ថប្រយោជន៍ផ្សេងៗដូចជាប្រាក់ទ្រទ្រង់សុខភាពចំនួន៥ដុល្លារ ,ប្រាក់រង្វាន់បំណាច់ឆ្នាំ១០ដុល្លារ ,ប្រាក់ឧបត្ថម្ភអាហារ៨ដុល្លារ និងប្រាក់ឧបត្ថម្ភធ្វើដំណើរចំនួន១៦ថ្ងៃស្មើនិង១៣ដុល្លារ សរុបចំនួន ៣០២.៤៧ ដុល្លារ រីប្រាក់ផ្សេងពីនេះ ដើមចោទមិនត្រូវទទួលបានទេ (តាមមាត្រា៦៧,៦៨ ,៨២និងមាត្រា១៦៦)នៃច្បាប់ស្តីពីការងារ។

តាមការពិនិត្យ ពិចារណា ឃើញថា បណ្តឹងទាមទាររបស់ដើមចោទ នត្ថិភាព ពុំគប្បីឱ្យតុលាការទទួលស្គាល់អង្គហេតុនេះ និងសម្រេចតាមច្បាប់បានទេ ។

យោងតាមមាត្រា ១០,៦៤,២៧,៦៧,៦៨,៨២ និងមាត្រា១៦៦ នៃច្បាប់ស្តីពីការ។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឱ្យក្រុមហ៊ុន[redacted]ដែលមានឈ្មោះ[redacted]HUO ជានាយកគ្រប់គ្រងក្រុមហ៊ុន[redacted]បើកប្រាក់ឱ្យទៅឈ្មោះ[redacted] សាបាន ដើមចោទ ដូចខាងក្រោម ៖

-ប្រាក់ខែចុងក្រោយចំនួន ១១៨.៧៧ (មួយរយដប់ប្រាំបី,ចិតសិបប្រាំពីរ)ដុល្លារអាមេរិក។

-ប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ចំនួន១៤៧.៧ (មួយរយសែសិបប្រាំពីរក្បៀសប្រាំពីរ) ដុល្លារអាមរិក ។

-ប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតដូចមានប្រាក់ទ្រទ្រង់សុខភាពចំនួន៥(ប្រាំ)ដុល្លារអាមេរិក ប្រាក់

វង្វាន់បំណាចឆ្នាំចំនួន១០(ដប់)ដុល្លារអាមេរិក ប្រាក់ឧបត្ថម្ភអាហារចំនួន៨ (ប្រាំបី) ដុល្លារអាមេរិក និងប្រាក់ឧបត្ថម្ភធ្វើដំណើរចំនួន១៦ថ្ងៃស្មើនឹង១៣(ដប់បី)ដុល្លារអាមេរិក ដែលមានទឹកប្រាក់សរុបចំនួន៣០២.៤៧ ដុល្លារអាមេរិក។ ការទាមទារលើសពីនេះសម្រេចច្រានចោល ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើ ។

៣. សាលក្រមនេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ខែកញ្ញាឆ្នាំ២០២២ និងប្រកាសសាលក្រមនៅថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០២២ ចំពោះមុខដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃពុធ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ស្វាយរៀង, ថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner